ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤. អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវដីសម្បទានសេដ្ឋកិច្ចដែលផ្តល់ ដល់ក្រុមហ៊ុនមៀវលីហេង ចំនួន៣.០០០ហិកតា ដើម្បីបង្វែរមកធ្វើជាប្រទានកម្ម ជូនប្រជាពលរដ្ឋកាន់កាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញសារាចរ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកៃលំអសោភ័ណ ភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខ ស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញកំណត់ហេតុចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១២ របស់គណៈកម្មការត្រួតពិនិត្យនិងកំណត់អត្ត សញ្ញាណដីនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម
- តាមសំណើលេខ ១៦២០ លខកច ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តកំពង់ចាម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### មាត្រា ១ ៖

ត្រូវបាននិរាករណ៍លិខិតលេខ ១៧៧៣ សជណ-ជស ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសុំដីសម្បទានចំនួន ៣.០០០ (បីពាន់) ហិកតាសម្រាប់ដាំដើមកៅស៊ូ នៅឃុំកំពាន់ ស្រុកមេមត់ ខេត្តកំពង់ចាម របស់ក្រុមហ៊ុនមៀងលីហោង ហើយកាត់ចេញពីផែនទីគម្រប ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ២០០២ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ ដែលបានកំណត់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 ដូចក្នុងផែនទី និងចំណុចគោលនៃ ក្បាលដីនីមួយៗ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ I នៃអនុក្រឹត្យនេះ និងដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y |
|---|---|---|
| 1 | 608578 | 1320319 |
| 2 | 612578 | 1320319 |
| 3 | 612578 | 1319319 |
| 4 | 612078 | 1319319 |
| 5 | 612078 | 1317319 |
| 6 | 612578 | 1317319 |

| ចំណុច | X | Y |
|---|---|---|
| 7 | 612578 | 1311319 |
| 8 | 610578 | 1311319 |
| 9 | 610578 | 1313319 |
| 10 | 609578 | 1313319 |
| 11 | 609578 | 1314319 |
| 12 | 608578 | 1314319 |

### មាត្រា ២ ៖

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម ធ្វើការគ្រប់គ្រងនិងធ្វើប្រទានកម្មផ្តល់ជូនប្រជាពលរដ្ឋចំនួន ១២៥០ (មួយពាន់ពីររយហាសិប)គ្រួសារ ដែលបានកាន់កាប់និងប្រើប្រាស់ដីនោះជាក់ស្តែង ដើម្បី មានសិទ្ធិកាន់កាប់ស្របច្បាប់ទៅតាមទំហំដីជាក់ស្តែង ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋនិងរដ្ឋបាល សុរិយោដីខេត្តកំពង់ចាមបានធ្វើការអង្កេតនិងវាស់វែងស្របតាមនីតិវិធីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋនិងអនុក្រឹត្យទាក់ទងនឹងការងារចុះបញ្ជីដីធ្លី

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកដីជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ ចាមត្រូវគិតបញ្ចូលនិងកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុក សម្រាប់ការអភិវឌ្ឍហេដ្ឋា រចនាសម្ព័ន្ធរូបវន្តសាធារណៈនិងសង្គមក្នុងមូលដ្ឋានផ្ទាល់ ។

### មាត្រា ៣ ៖

ក្នុងពេលរង់ចាំដំណើរការចុះបញ្ជីដីធ្លីតាមនីតិវិធីបានបញ្ចប់ជាស្ថាពរ គណៈកម្មាធិការគ្រប់គ្រងដី រដ្ឋខេត្តកំពង់ចាមត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋមលើដីនោះ ដូចមានគម្រូក្នុងឧបសម្ព័ន្ធ III នៃអនុក្រឹត្យនេះ

ដល់ប្រជាពលរដ្ឋដែលទទួលបានដី ក្នុងនោះត្រូវធ្វើប្រទានកម្មជាកម្មសិទ្ធិឯកជនលើចំណែកដីមិនលើសពី ០៥ (ប្រាំ) ហិកតា លើកលែងតែដីដែលបានដាំដំណាំរួច ដូចជាកៅស៊ូជាដើម អាចផ្តល់ជាកម្មសិទ្ធិឯកជនក្នុងទំហំមិនលើសពី ២០០ (ពីររយហិកតា) ។

**មាត្រា ៤ ៖**

ចំណែកដីនៅសល់ពីការធ្វើប្រទានកម្មដូចចែងក្នុងមាត្រា ៣ ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ចាម និងអាចផ្តល់ប្រទានកម្មនូវសិទ្ធិសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដោយត្រូវផ្តល់លិខិតបញ្ជាក់ការប្រើប្រាស់ដីរដ្ឋក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដូចមានគម្រូក្នុងឧបសម្ព័ន្ធទី III នៃអនុក្រឹត្យនេះ នៅក្នុងពេលរង់ចាំការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាផ្លូវការ ។

**មាត្រា ៥ ៖**

កម្រៃសេវាសុរិយោដី និងកាតព្វកិច្ចពន្ធផ្សេងៗដែលមានជាប់ពាក់ព័ន្ធជាបន្ទុករបស់រដ្ឋ លើកលែងតែករណីសម្បទានដីសេដ្ឋកិច្ចខ្នាតតូច គឺត្រូវអនុវត្តកាតព្វកិច្ចតាមខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដូចមានគម្រូជាឧបសម្ព័ន្ធទី IV នៃអនុក្រឹត្យនេះ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ពន្ធ័ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ